# ពិធីបុណ្យអុំទូកនៅស្ទឹងស្ទោង

ស្ទឹងស្ទោង គឺជាខ្សែទឹកដ៏សំខាន់មួយដែលមានប្រភពមកពីជួរភ្នំត្បែង ខេត្តព្រះវិហារ ហូរកាត់ស្រុកសង្គមថ្មី ស្រុកប្រាសាទបល្ល័ង្ក និងស្រុកស្ទោង បន្តទៅដល់បឹងទន្លេសាប ដែលមានប្រវែងសរុបប្រមាណ ១០០គីឡូម៉ែត្រ។[១] ការប្រារព្ធពិធីបុណ្យអុំទូកនៅស្ទឹងស្ទោង គេធ្វើឡើងនៅទីប្រជុំជនស្រុកស្ទោង ពោល គឺភូមិកំពង់ចិន (ត្រង់ចំណុចវត្តក្តីដើម) ដែលជាទីតាំងមជ្ឈមណ្ឌលសេដ្ឋកិច្ច និងពាណិជ្ជកម្មដ៏សំខាន់របស់ស្រុកស្ទោង តភ្ជាប់ទំនាក់ទំនងរវាងអ្នកខាងលើ (អ្នកអាស្រ័យផលអនុផលព្រៃឈើ) និងអ្នកខាងក្រោម (អ្នកនេសាទនៅបឹងទន្លេសាប)។ តើពិធីបុណ្យអុំទូកនៅស្ទឹងស្ទោងមានលក្ខណៈបែបណាខ្លះ?

បុណ្យអុំទូក គឺជាទំនៀមពិសេសរបស់អ្នកស្រុកទាំងឡាយដែលនៅជាប់មាត់ទឹក តួយ៉ាងមាត់ស្ទឹង បឹង ទន្លេ ហើយជាទូទៅអ្នកស្រុកនៅជាប់ទន្លេតែងប្រារព្ធបុណ្យនេះនៅថ្ងៃចេញវស្សា។ ចំណែកឯពិធីបុណ្យអុំទូកថ្នាក់ជាតិដែលរៀបចំនៅមុខព្រះបរមរាជវាំង គេតែងប្រារព្ធនៅថ្ងៃ១៤កើត ដល់ថ្ងៃ១រោច ខែកត្តិក ដែល១៥កើតជាថ្ងៃពេញបូណ៌មី។[២] ប៉ុន្តែ ពិធីបុណ្យអុំទូកនៅស្ទឹងស្ទោង ដែលប្រារព្ធឡើងនៅខាងមុខវត្តក្តីដើមនេះ គេតែងប្រារព្ធឡើងបន្ទាប់ពីចប់ពិធីភ្ជុំបិណ្ឌ ដោយគេធ្វើឡើងចំនួន ៣ថ្ងៃ ចាប់ពីថ្ងៃ១កើត ដល់ថ្ងៃ៣កើត ខែអស្សុជ។ ដូចពោលមកខាងលើស្រាប់ ស្ទឹងស្ទោងមានទំនាក់ទំនងជិតស្និទ្ធជាមួយមនុស្សនៅក្នុងសហគមន៍ខ្លាំងណាស់ ពោល គឺទាំងអ្នកនៅខាងលើ និងនៅខាងក្រោម តែងតែពឹងផ្អែកជាសំខាន់ទៅលើទឹកស្ទឹងស្ទោងដែលជាប្រភពផ្តល់នូវជីវិតសម្រាប់អ្នកស្រុកស្ទោងទាំងមូល។ ម្ល៉ោះហើយ ពិធីបុណ្យអុំទូកនេះ មិនសូវខុសប៉ុន្មានពីអ្នកស្រុកជាប់មាត់ទន្លេទេ ពោល គឺជាប់ទាក់ទងជាមួយនឹងទឹក ហើយគោលបំណងនៃកិច្ចនេះពុំមែនគិតលើរឿងឈ្នះចាញ់អ្វីឡើយ។ ប៉ុន្តែ វាជាកិច្ចមួយដែលធ្វើឡើងដើម្បីបណ្តេញទឹកយកដីធ្វើកសិកម្ម ដោយហេតុថានៅដើមខែអស្សុជជាពេលដែលទឹកទន្លេធ្លារនិងទន្លេសាបនៅផ្នែកខាងក្រោមឡើងប្រាលមកលើ។

ទូកដែលគេយកមកអុំ ជាទូកតូចៗដែលច្រើនតែជាប្រភេទទូកផ្កាចារ ទូកង និងទូកកំរោល ហើយជាទូទៅកាលពីដើមមកមានទូកប្រមាណ ១០ ទៅ ២០ ប៉ុណ្ណោះដែលមកចូលរួម ប៉ុន្តែសព្វថ្ងៃ ទូកបានកើនឡើងរហូតដល់ជិត ៤០ទូក។ ក្នុងនោះដែរ វត្តក្តីដើមដែលជាទីតាំងប្រារព្ធពិធី

---

[១] Dufosse 1918: 10.

[២] ពុទ្ធសាសនបណ្ឌិត្យ ១៩៦០: ១២០។

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

កាលពីដើមមកមានទូកចំនួន ៣ ដែលមានឈ្មោះ "អាពប", "អាមាន់ហើរ" និង "អាខ្នុរ"។ គួរឱ្យសោកស្ដាយ ទូកទាំង ៣ នេះ គេវាយកំទេចចោលអស់នៅសម័យកម្ពុជាប្រជាធិបតេយ្យ។ សព្វថ្ងៃនៅសល់តែបំណែកក្បែកទូកឈ្មោះ "អាពប" មួយចំហៀងប៉ុណ្ណោះដែលរក្សាទុកនៅក្នុងវត្ត និងបំណែកក្បែកទូកមួយចំហៀងទៀតអ្នកស្រុកយកទៅរក្សាទុក ហើយចំណែកទូកឈ្មោះ "អាខ្នុរ" នៅសល់តែក្បាលទូកប៉ុណ្ណោះដែលគេយកទៅរក្សាទុកនៅភូមិសល្វាចស្ថិតនៅខាងជើងវត្តក្ដីដើម ប្រមាណ ៤គីឡូម៉ែត្រ។ ជាទំនៀមតរៀងមក នៅថ្ងៃទី១នៃពិធីបុណ្យអុំទូកនេះ ចំណុះទូកទាំងអស់ និងអ្នកចូលរួម ចាប់ផ្ដើមជួបជុំគ្នានៅខាងមុខខ្ទមអ្នកតាគង់ដែលស្ថិតនៅខាងកើតព្រះវិហារវត្តក្ដីដើម (បរិវេណវត្ត) នៅម៉ោងប្រមាណ ១រសៀល។ កាលពីដើមមក គេមានថ្វាយភ្លេង បញ្ចាន់រូបដោយមានអ្នកស្នងរូបម្នាក់ឈ្មោះ "យាយតែម" រាំតំណាងនៅខាងមុខខ្ទមអ្នកតាគង់។ ពេលអ្នកតាគង់ចូលរូបម្ដងៗ អ្នកចូលរួមតែងសួរទៅរូបស្នងថា "តើអ្នកតាគង់មែនទេ?" ហើយរូបស្នងតបថា "មិនដឹងទេ"។ បន្ទាប់មក យាយតែមដែលជារូបស្នង ត្រូវឡើងរាំជិះលើទូកមួយជុំសិនមុននឹងចាប់ផ្ដើមកម្មវិធីបុណ្យអុំទូក។ គួរឱ្យសោកស្ដាយ ចាប់តាំងពីយាយតែមបានលាចាកលោកទៅ មិនមានអ្នកស្នងរូបក្នុងកិច្ចនេះទៀតឡើយ។ ម្ល៉ោះហើយ គេជ្រើសរើសយកចំណុះទូកណាម្នាក់ចងក្រណាត់ក្រហមលើក្បាល និងចំណុះទូកផ្សេងទៀតមកតុបតែងខ្លួន លាបម្សៅពេញមុខ មកសែនព្រេន និងរាំថ្វាយអ្នកតាគង់ (រូបលេខ១)។ ការបួងសួង និងរាំរែកនៅមុខខ្ទមអ្នកតាគង់ គេធ្វើបីថ្ងៃពេញតែម្ដង ពោល គឺមុននឹងចាប់ផ្ដើមអុំទូក គេមានទំនៀមមកសែនព្រេនដល់អ្នកតាគង់ជាមុនសិន (រូបលេខ២-៦)។

តាមទម្លាប់ពីដើមមក នៅមុនពេលអុំទូក គេតែងអុំទូកឈ្មោះ "អាពប" ចេញពីវត្តក្ដីដើមទៅយកចំណុះទូកផ្សេងទៀតនៅម្ដុំវត្តហប់ដែលស្ថិតនៅទិសឦសានវត្តក្ដីដើម។ ប៉ុន្តែ សព្វថ្ងៃមិនមានពិធីអុំទូកឈ្មោះ "អាពប" ទៅយកទៀតទេ ដ្បិតទូកនេះគេវាយចោលជាយូរមកហើយដូចរៀបរាប់ខាងលើស្រាប់។ ដោយឡែក នៅឆ្នាំ២០២០ គណៈកម្មាធិការគ្រប់គ្រងវត្តបានធ្វើទូកថ្មីចំនួន ២ ដោយដាក់ឈ្មោះចាស់ដដែល គឺឈ្មោះ "អាពប" និង "អាមាន់ហើរ"។ ពិធីបុណ្យអុំទូកនេះជក់ជាប់ក្នុងផ្នត់គំនិតអ្នកស្រុកខ្លាំងណាស់ ទើបបានគេគូរគំនូររូបទូកនៅលើជញ្ជាំងព្រះវិហារវត្តក្ដីដើម ផ្នែកខាងជើង (រូបលេខ៧-៨)។

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ១៖ ចំណុះទូក និងអ្នកចូលរួម បួងសួង រាំរែក ថ្វាយអ្នកតាគង់ ក្នុងបរិវេណវត្តក្តីដើម



រូបលេខ២៖ ទិដ្ឋភាពក្នុងថ្ងៃបុណ្យអុំទូកនៅស្ទឹងស្មោង

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ២៣៖ ទិដ្ឋភាពពេលកំពុងអុំទូក



រូបលេខ២៤៖ ទិដ្ឋភាពពេលកំពុងអុំទូក

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ២៥៖ ទិដ្ឋភាពពេលកំពុងអុំទូក




រូបលេខ២៦៖ ព្រះគ្រូចៅអធិការវត្តចែកអំណោយដល់ចំណុះទូកនៅថ្ងៃអុំទូកផ្តាច់ព្រ័ត្រ

អត្ថបទដោយ៖ ម៉ង់ រ៉ាលី



រូបលេខ៧៖ ទូកឈ្មោះ "អារាប" គំនូរលើជញ្ជាំងព្រះវិហារវត្តក្តីដើម



រូបលេខ៨៖ ទូកឈ្មោះ "អាមាន់ហើរ" គំនូរលើជញ្ជាំងព្រះវិហារវត្តក្តីដើម

## ឯកសារយោង


ពុទ្ធសាសនបណ្ឌិត្យ (១៩៦០), *ព្រះរាជពិធីទ្វាទសមាស*, ភាគ ៣, ភ្នំពេញ

**Dufosse, M.** (1918), *Monographie de la circonscription résidentielle de Kompong-Thom*, Paris


អត្ថបទដោយ៖ ម៉ង់ វ៉ាលី